**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអភិវឌ្ឍន៍ជនបទ**
**គម្រោងកែលម្អការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់** (RCIP)

# សេចក្តីប្រកាសជ្រើសរើសបុគ្គលិក

## អ្នកបើកបរចំនួន ៣រូប (បន្ថែម)

## អ្នកអនាម័យចំនួន ១រូប (បន្ថែម)

គម្រោងកែលម្អការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ មានសមាសភាគចំនួនបួនគឺ÷ (១) ការកែលម្អផ្លូវជាតិ និងផ្លូវខេត្ត (២) ការកែលម្អផ្លូវជនបទ (៣) ការអភិវឌ្ឍស្ថាប័ន និងការគ្រប់គ្រងគម្រោង និង (៤) ការឆ្លើយតបជាបន្ទាន់។ ក្រសួងអភិវឌ្ឍន៍ជនបទ ជាភ្នាក់ងារអនុវត្តសមាសភាគទី២ ÷ ការកែលម្អផ្លូវជនបទ ដែលមានភាពធននឹងការប្រែប្រួលអាកាសធាតុនៅក្នុងខេត្តគោលដៅចំនួន ៣គឺ ខេត្តក្រចេះ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ។ គម្រោងនេះចាប់អនុវត្តនៅចន្លោះខែកក្កដា ឆ្នាំ២០២០ ដល់ខែកក្កដា ឆ្នាំ២០២៧។ ដើម្បីគាំទ្រ និងសម្រួលដល់ដំណើរការអនុវត្តគម្រោងប្រចាំថ្ងៃ និងការចុះបេសកកម្មនៅតាមខេត្តគោលដៅ គម្រោងសូមប្រកាសជ្រើសរើសបុគ្គលិកបំពេញបន្ថែមសម្រាប់មុខតំណែងដូចខាងក្រោម ÷

| មុខតំណែង | ចំនួន | បៀវត្ស/ខែ | ទីកន្លែងបំពេញការងារ |
|---|---|---|---|
| អ្នកបើកបរ | ៣រូប | ២៥០ ដុល្លារអាមេរិក | គម្រោង (RCIP) និងខេត្តគោលដៅ |
| អ្នកអនាម័យ | ១រូប | ១៥០ ដុល្លារអាមេរិក | បន្ទប់នាយកគម្រោង និងនាយករង |

### ១. លក្ខខណ្ឌនៃការជ្រើសរើស

### ១.១. អ្នកបើកបរ

- មានអាយុចាប់ពី ២០ឆ្នាំ - ៥៥ឆ្នាំ
- មានអត្តចរិកល្អ ស្លូតត្រង់ អាចធ្វើការងារជាក្រុម
- មានកាយសម្បទាគ្រប់គ្រាន់ មិនធ្លាប់ពាក់ព័ន្ធនឹងអំពើមិនសមស្របច្បាប់ណាមួយ
- មានចំណេះដឹងផ្នែកបើកបរ (មានប័ណ្ណបើកបរ ដែលមានសុពលភាព)
- មានបទពិសោធន៍យ៉ាងតិច ២ឆ្នាំឡើងទៅ ជាមួយគម្រោងរាជរដ្ឋាភិបាល ស្ថាប័នឯកជន ឬអង្គការអន្តរជាតិនានា

- ចេះអាន និងសរសេរអក្សរខ្មែរបានត្រឹមត្រូវ និងច្បាស់លាស់។

**១.២. អ្នកអនាម័យ**

- មានអាយុចាប់ពី ១៨ឆ្នាំ - ៦០ឆ្នាំ
- មានអត្តចរិកល្អ ស្លូតត្រង់ ស្មោះត្រង់ អាចធ្វើការងារជាក្រុម
- មានកាយសម្បទាគ្រប់គ្រាន់ មិនធ្លាប់ពាក់ព័ន្ធនឹងអំពើមិនសមស្របច្បាប់ណាមួយ
- មានបទពិសោធន៍ក្នុងការងារអនាម័យយ៉ាងតិច ២ឆ្នាំឡើងទៅ
- ចេះអាន និងសរសេរអក្សរខ្មែរបានត្រឹមត្រូវ និងច្បាស់លាស់

សូមមើលតួនាទី និងភារកិច្ចទទួលខុសត្រូវលម្អិត (TOR) និងតម្រូវការគុណសម្បត្តិសម្រាប់មុខតំណែងខាងលើ នៅក្នុងគេហទំព័ររបស់ក្រសួងអភិវឌ្ឍន៍ជនបទ www.mrd.gov.kh ។

**២. អំពីការដាក់ពាក្យ**

បេក្ខជន-បេក្ខនារីដែលមានចំណាប់អារម្មណ៍ សូមផ្ញើប្រវត្តិរូបសង្ខេប (CV) ដោយមានបញ្ជាក់អំពីព័ត៌មានសម្រាប់ទំនាក់ទំនង (រួមមាន÷ អាសយដ្ឋាន លេខទូរស័ព្ទ ឬអ៊ីម៉ែល) មកកាន់ផ្នែករដ្ឋបាលរបស់គម្រោង RCIP-MRD រៀងរាល់ម៉ោងធ្វើការ ឬតាមរយៈសារអេឡិចត្រូនិច (Email) engdiman.mrd@gmail.com ។

ឈប់ទទួលពាក្យ÷ **ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៤ វេលាម៉ោង ១៧ :០០ រសៀល** តាមអាសយដ្ឋានក្រសួងអភិវឌ្ឍន៍ជនបទ អគារលេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ (ជាន់ទី៦ បន្ទប់ ៦១០)។

**បញ្ជាក់ ÷** មុខតំណែងនេះជាប្រភេទកិច្ចសន្យា ដូច្នេះបេក្ខជនដែលនឹងត្រូវជ្រើសរើសឱ្យបំពេញការងារ ត្រូវតែមិនមែនជាមន្ត្រីរាជការស៊ីវិល។ ក្នុងករណីដែលបេក្ខជនជាមន្ត្រីរាជការស៊ីវិល បេក្ខជននោះត្រូវដាក់ពាក្យសុំស្ថិតនៅក្នុងភាពទំនេរគ្មានប្រាក់បៀវត្ស ក្នុងរយៈពេលនៃការបំពេញការងារជាមួយគម្រោង។